ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ធទឧ

# សេចក្តីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការតាមដានស្រាវជ្រាវពីស្ថានភាពធាតុអាកាសរួចមក ឃើញថា បច្ចុប្បន្នជ្រលងសម្ពាធខ្ពស់ ដែលកើតឡើងដោយសម្ពាធខ្ពស់នៅលើប្រទេសចិនបាន និងកំពុងរំកិលខ្លួនមកគ្របដណ្តប់លើព្រះរាជាណាចក្រកម្ពុជា ។ ឥទ្ធិពលនៃជ្រលងសម្ពាធខ្ពស់នេះបានបង្កឱ្យធាតុអាកាស និងសីតុណ្ហភាពចុះត្រជាក់ខុសពីធម្មតា ចាប់ពីខែវិច្ឆិកា ឆ្នាំ 2010 ដល់ពាក់កណ្តាលខែមករា ឆ្នាំ 2011 ។ សីតុណ្ហភាពអប្បបរមា នៅតាមតំបន់នឹងមានដូចខាងក្រោម ៖

- **តំបន់ភ្នំ និងតំបន់ខ្ពង់រាប ៖** មានខេត្តព្រះវិហារ ស្ទឹងត្រែង ក្រចេះ កំពង់ចាម រតនគិរី មណ្ឌលគិរី សីតុណ្ហភាពអប្បបរមា អាចចុះត្រជាក់ដល់ 13-15 អង្សារសេ ។
- **តំបន់វាលទំនាប ៖** មានខេត្តសៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង ពោធិ៍សាត់ កំពង់ធំ និងកំពង់ឆ្នាំង សីតុណ្ហភាពអប្បបរមា អាចចុះត្រជាក់ដល់ 16-18 អង្សារសេ ។ ដោយឡែកចំពោះរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ ព្រៃវែង ស្វាយរៀង និងបណ្តាខេត្តជាប់តំបន់មាត់សមុទ្រសីតុណ្ហភាពអប្បបរមា អាចចុះត្រជាក់ ដល់ 18-20 អង្សារសេ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០១០

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh